ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ២ ៣ ២ ២ ៤ កសក

រាជធានីភ្នំពេញ, ថ្ងៃទី..១.២.ខែ..ធ្នូ...ឆ្នាំ២០១៦.

សូមគោរពជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

កម្មវត្ថុ: របាយការណ៍អំពីស្ថានភាពនៃការបំពេញបែបបទនាំចេញអង្ករក្នុងរយៈពេល៣ខែដើមឆ្នាំ២០១៦។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទសូមអនុញ្ញាតជម្រាបជូន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ជាទីគោរពដ៏ខ្ពង់ខ្ពស់មេត្តាជ្រាបថា នៅរយៈពេល៣ខែដើមឆ្នាំ២០១៦នេះ ស្ថានភាពនៃការនាំចេញអង្ករទៅក្រៅប្រទេសដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទទួលបានដោយផ្អែកលើប្រព័ន្ធទិន្នន័យគ្រឹះភូតគាមអនាម័យជាតិ National Phytosanitary database (NPD/GDA from 07:00/01.01.2016 to 17:00/31.03.2016) ដែលជាតួលេខនៃការនាំចេញតាមរយៈការរៀបចំវេចខ្ចប់គ្រប់ចំនួនរួចជាស្រេច និងបានឆ្លងកាត់ការត្រួតពិនិត្យភូតគាមអនាម័យដើម្បីនាំចេញមានដូចខាងក្រោម៖

១ - ស្ថានភាពនៃការនាំចេញអង្ករ

- បរិមាណអង្ករនាំចេញមានចំនួន១៦២.២២០តោន មានការកើនឡើងចំនួន១២.៧៥៦តោន (+៨,៥%) លើសបរិមាណនាំចេញរយៈពេល៣ខែដើមឆ្នាំ២០១៥ ដែលនាំចេញបានតែ១៤៩.៤៦៤តោន (សូមបង្ហាញជូនក្នុងតារាងទី១នៃឧបសម្ព័ន្ធ)

- អង្ករក្រអូបគ្រប់ប្រភេទមានបរិមាណនាំមុខគេដែលមានកំណើនកើនឡើងរហូតដល់ ៧២.៣៤៤តោន ស្មើនឹង៤៤,៦% អង្ករសគ្រប់ប្រភេទមានចំនួន៧៨.១០៩តោន ស្មើនឹង៤៨,២% និង អង្ករចំហុយ ១១.៧៦៧តោន ស្មើនឹង៧,២%។ ក្នុងចំណោមអង្ករក្រអូបនោះ អង្ករផ្កាម្លិះ (Jasmine rice) និងផ្ការំដួលមានបរិមាណ ១៧.៦១២តោន (លំដាប់ទី១) អង្ករក្រអូបចម្រុះ (នាងក្រអូប នាងសយ និងពូជដទៃ) មាន៦.៧១៩តោន (លំដាប់ទី២) អង្ករក្រអូបនាងម្លិះមាន៩១៥តោន (លំដាប់ទី៣) អង្ករក្រអូបសរីរាង្គមាន ៤០៥តោន (លំដាប់ទី៤) និងសូមាលីមាន ២៤០ តោន (លំដាប់ទី៥) (សូមបង្ហាញជូនក្នុងតារាងទី២នៃឧបសម្ព័ន្ធ)

- អង្ករកម្ពុជាបាននាំចេញទៅកាន់ទិសដៅចំនួន៤៧ប្រទេស ក្នុងនោះប្រទេសចិនឈរលំដាប់ទី១ (៣៧.១១៨តោន) ប្រទេសបារាំងឈរលំដាប់ទី២ (២០.៩៩៦តោន) ប្រទេសប៉ូឡូញឈរលំដាប់ទី៣ (១៨.២១២ តោន) ប្រទេសនីដ័រឡេនឈរលំដាប់ទី៤ (៨.៣០៧តោន) ប្រទេសម៉ាឡេស៊ីឈរលំដាប់ទី៥ (៨.២១០តោន) ប្រទេសអង់គ្លេសឈរលំដាប់ទី៦ (៧.៩៥៦តោន) សាធារណរដ្ឋឆេកឈរលំដាប់ទី៧ (៦.១៨៤តោន) ប្រទេសបែលហ្ស៊ិកឈរលំដាប់ទី៨ (៥.៨៩៧តោន) ប្រទេសហុងគ្រីឈរលំដាប់ទី៩ (៥.៨៣៥តោន) និងប្រទេសអ៊ីតាលីឈរលំដាប់ទី១០ (៥.៥១៧តោន)។ បរិមាណអង្ករដែលនាំចេញទៅកាន់ប្រទេសជាទិសដៅសហគមន៍អឺរ៉ុប២៥ ប្រទេស មានបរិមាណសរុប ១០៣.៧៧៩តោន (៦៤%) ទិសដៅអាស៊ាន៣ប្រទេសមានបរិមាណសរុប១៤.៩៦៤ តោន (៩,២%) និងទិសដៅដទៃទៀត១៩ប្រទេសមានបរិមាណសរុប៤៣.៤៧៧តោន (២៦,៨%) (សូមបង្ហាញជូនក្នុងតារាងទី៣នៃឧបសម្ព័ន្ធ)

- ការនាំចេញអង្ករមាន៦២ក្រុមហ៊ុន ដែលបរិមាណអង្ករនាំចេញត្រូវបាននាំមុខគេដោយ៖ (ទី១).ក្រុមហ៊ុន Khmer Food group មានចំនួន ២០.៨៧២តោន (ទី២).ក្រុមហ៊ុន Nicoline Investment មានចំនួន ១៧.៨៤៥តោន

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
N° 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ: (0២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ: (៨៥៥) ២៣-២១៧ ៣២០
Phone: (023) 726 128 / 726 129, Fax: (855) 23 - 217 320

(ទី៣).ក្រុមហ៊ុន Baitang Kampuchae មានចំនួន ១២.៣៣១តោន (ទី៤).ក្រុមហ៊ុន Amru Rice មានចំនួន ១១.៤៦៣តោន (ទី៥).ក្រុមហ៊ុន Cristal Rice មានចំនួន ៩.៥៩៨តោន (ទី៦). ក្រុមហ៊ុន City Rice Import Export មានចំនួន ៨.០០៤តោន (ទី៧). ក្រុមហ៊ុន TOT មានចំនួន ៧.៨១២តោន (ទី៨).ក្រុមហ៊ុន International Rice Trading មានចំនួន៧.៧០៩តោន (ទី៩).ក្រុមហ៊ុន Golden Rice មានចំនួន៧.០៩៦តោននិង (ទី១០).ក្រុមហ៊ុន Signatures of Asia មានចំនួន ៦.៥២១តោន (សូមបង្ហាញជូនក្នុងតារាងទី៤នៃឧបសម្ព័ន្ធ) ។

២ - សន្និដ្ឋាន៖

បរិមាណអង្ករនាំចេញសរុបក្នុងរយៈពេល៣ខែដើមឆ្នាំ២០១៦ មានចំនួន១៦២.២២០តោន ដែលបរិមាណនេះមានកំណើនប្រមាណ ៨,៥% ធៀបនឹងបរិមាណនាំចេញរយៈពេល៣ខែដើមឆ្នាំ២០១៥។

លេខាធិការដ្ឋានច្រកចេញចូលតែមួយសម្រាប់បំពេញបែបបទនាំចេញអង្ករ ដែលជាសេនាធិការ របស់ក្រុមការងារទី ៩ និងខិតខំបន្តពង្រីកវិសាលភាពដើម្បីបំពេញតួនាទីក្នុងការបង្កើនការយល់ដឹងដល់អ្នកពាក់ព័ន្ធ (សមត្ថកិច្ចដែលពាក់ព័ន្ធនឹងបែបបទនាំចេញអង្ករ ក្រុមហ៊ុននាំចេញអង្ករ រោងម៉ាស៊ីនកិនស្រូវ និងកែច្នៃអង្ករ ក្រុមហ៊ុនដឹកជញ្ជូន។ល។ ដែលកំពុងមានសកម្មភាពពាក់ព័ន្ធនឹងការនាំចេញអង្ករ) ក្នុងការរៀបចំថៃទាំស្រូវ អង្ករមុនការនាំចេញ និង បំពេញបែបបទដោយអនុលោមតាមលក្ខខ័ណ្ឌតម្រូវរបស់ប្រទេសនាំចូល និងរាល់កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជាជាមួយប្រទេសនាំចូលឲ្យបានសមស្របតាមស្តង់ដារភូតគាមអនាម័យទាំងបរិមាណ គុណភាព និងនីតិវិធីជាធរមាន។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ ខ្ញុំបាទសូម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ជាទីគោរពដ៏ខ្ពង់ខ្ពស់មេត្តាជ្រាបជាសេចក្តីរាយការណ៍ដោយក្តីអនុគ្រោះ។

សូម **សម្តេចតេជោ នាយករដ្ឋមន្ត្រី** មេត្តាទទួលនូវសេចក្តីគោរពដ៏ជ្រាលជ្រៅបំផុតអំពីខ្ញុំបាទ។

រដ្ឋមន្ត្រី
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

យុទ្ធ ភូថង

ចម្លងជូន:
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
  "ដើម្បីជូនជ្រាប"
- អគ្គនាយកដ្ឋានកសិកម្ម
- នាយកដ្ឋានផែនការនិងស្ថិតិ
  "ដើម្បីជ្រាប"
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធ: របាយការណ៍អំពីស្ថានភាពនៃការនាំចេញអង្ករកម្ពុជាប្រចាំខែមីនាឆ្នាំ២០១៦

(ANNEX: THE REPORT ON CAMBODIAN RICE EXPORT STATUS IN MARCH, 2016)

(Base on NPD/GDA from 07:00/01.01.2016 to 17:00/31.03.2016 and all number are English punctuation)

តារាងទី១.បរិមាណអង្ករកម្ពុជាដែលបាននាំចេញប្រចាំខែ ក្នុងឆ្នាំ ២០១២ - ២០១៦, គិតជាតោន

(Table1. Quantity of Cambodian Rice have been Exported by months of 2012-2016, in tones)

	Month/ Year	2012	2013	2014	2015	2016	VARIATION
1	មករា (January)	9,703	25,726	21,536	35,921	44,033	+22.60%
2	កុម្ភៈ (February)	14,417	24,089	27,037	37,676	51,912	+37.80%
3	មីនា (March)	12,310	45,413	35,757	75,867	66,275	-14.50%
	Sub-Total for 3 months	36,430	95,228	84,330	149,464	162,220	+8.50%
4	មេសា (April)	15,036	23,276	35,961	51,719		
5	ឧសភា (May)	13,115	28,350	27,971	41,842		
6	មិថុនា (June)	13,426	29,105	29,666	40,800		
7	កក្កដា (July)	20,527	31,411	26,060	28,492		
8	សីហា (August)	15,530	29,358	29,871	29,819		
9	កញ្ញា (September)	15,169	29,395	35,511	26,969		
10	តុលា (October)	16,967	28,031	35,418	39,064		
11	វិច្ឆិកា (November)	25,189	37,855	31,137	48,748		
12	ធ្នូ (December)	34,328	46,847	51,136	81,479		
GRAND TOTAL		205,717	378,856	387,061	538,396		

តារាងទី២.ប្រភេទអង្ករកម្ពុជាដែលបាននាំចេញក្នុង៣ខែដើមឆ្នាំ ២០១៦, គិតជាតោន

(Table 2. Type of Cambodian Rice have been Exported in March 2016, in tones)

	ប្រភេទអង្ករ TYPE OF RICE	មករា JAN	កុម្ភៈ FRA	មីនា MAR	សរុប (TOTAL) MT	%
I. អង្ករក្រអូប /JASMINE/ FRAGRANT RICE:						
1	ចម្រុះ (F.SENKRAOB, NEANG SAUY....)	5,888	7,024	6,719	19,631	12.1
2	នាងម្ជិស (F. NEANG MALIS)	1,787	1,207	915	3,909	2.4
3	សូមាលី .(F. SOMALY)	214	216	240	670	0.4
4	ផ្កាវ៉ដ្ឍល /ផ្កាម្ជិស/ (J.PHKA RUMDUOL/ MALIS)	14,672	13,629	17,612	45,913	28.3
5	សរីរាង្គ (J.ORGANIC)	414	180	405	999	0.6
6	ភ្លឺ . (F. PEARL)	48	920	254	1,222	0.8
	SUB-TOTAL	23,023	23,176	26,145	72,344	44.6
II.អង្ករសគ្រាប់វែង /WHITE LONG GRAIN RICE:						
1	ចម្រុះគ្រាប់វែង (LONG GRAIN)	18,310	24,878	32,759	75,947	46.9
2	ប្រណិតគ្រាប់វែង (PREMIUM LONG GRAIN)	445	488	1,229	2,162	1.3
	SUB-TOTAL	18,755	25,366	33,988	78,109	48.2
III.អង្ករចំហុយគ្រាប់វែង/ LONG GRAIN PABOILLED:						
1	ចំហុយគ្រាប់វែង (LONG GRAIN PABOILLED)	2,255	3,370	6,142	11,767	7.2
	SUB-TOTAL	2,255	3,370	6,142	11,767	7.2
GRAND TOTAL		44,033	51,912	66,275	162,220	100

តារាងទី៣. ទិសដៅនៃការនាំចេញអង្ករកម្ពុជាក្នុងរយៈពេល ៣ខែដើមឆ្នាំ ២០១៦, គិតជាតោន

(Table 3. Export Destination of Cambodian Rice 3 Month of 2016, in tones)

	ប្រទេសទិសដៅ	មករា	កុម្ភៈ	មីនា	មេសា	ឧសភា	មិថុនា	សរុប
	COUNTRY DESTINATION	JAN	FEB	MAR	APR	MAY	JUN	TOTAL
	I.សមាជិកសហគមន៍អឺរ៉ុប /EUROPEAN UNION							
1	FRANCE	6,386	6,068	8,542				20,996
2	POLAND	5,538	5,246	7,428				18,212
3	NETHERLAND	2,503	2,133	3,671				8,307
4	UNITED KINGDOM	2,074	2,512	3,370				7,956
5	CZECH REPUBLIC	1,232	2,147	2,805				6,184
6	BELGIUM	1,017	2,435	2,445				5,897
7	HUNGARY	1,300	1,915	2,620				5,835
8	ITALY	1,912	1,664	1,941				5,517
9	GERMANY	1,631	1,499	1,691				4,821
10	ROMANIA	2,764	196	288				3,248
11	SPAIN	847	1,073	1,154				3,074
12	BULGARIA	900	1,250	123				2,273
13	PORTUGAL	50	1,304	704				2,058
14	SWEEDEN	596	520	784				1,900
15	GREECE	361	636	901				1,898
16	DENMARK	215	485	908				1,608
17	CROATIA	450	425	650				1,525
18	LATIVA		400	425				825
19	SLOVENIA		96	408				504
20	LITHUANIA		300	144				444
21	ESTONIA			250				250
22	CYPRUS	24	72	100				196
23	AUSTRIA	72		73				145
24	FINLAND	24		40				64
25	IRELAND		24	18				42
	SUB-TOTAL	**29,896**	**32,400**	**41,483**				103,779
	II. សមាជិកអាស៊ាន/ASEAN MEMBER STATE							
1	MALAYSIA	2,736	3,266	2,208				8,210
2	BRUNEI	1,974		3,948				5,922
3	SINGAPORE	418	171	243				832
	SUB-TOTAL	5,128	3,437	6,399				14,964
	III.ទិសដៅផ្សេងទៀត /OTHERS DESTINATION							
1	CHINA	6,999	13,437	16,682				37,118
2	GABON	518	1,034	517				2,069
3	HONG KONG	373	310	447				1,130
4	AUSTRALIA	229	168	148				545
5	TURKY		500					500
6	ANGOLA	300	50	150				500
7	RUSSIAN FED	200	200	75				475
8	USA	57	143	136				336
9	IRAQ	230						230
10	MAYOTTE	50		75				125
11	NEWZEALAND		45	71				116
12	CANADA	20	42	42				104
13	SWITZERLAND	26	72					98
14	LEBANON		25					25
15	NAMIBIA		25					25
16	SENEGAL			25				25
17	MAURITINIA			25				25
18	ISRAEL		24					24
19	JAPAN	7						7
	SUB-TOTAL	9,009	16,075	18,393				43,477
	GRAND TOTAL	44,033	51,912	66,275				162,220

តារាងទី ៤. ក្រុមហ៊ុននិងបរិមាណដែលបានធ្វើការនាំចេញអង្ករកម្ពុជា ៣ខែដើមឆ្នាំ ២០១៦,គិតជាតោន និង %

(Table 4.Cambodian Rice Exporters and export quantity in 3 Months of 2016, in tones & % share)

	ក្រុមហ៊ុននាំចេញអង្គរ	មករា	កុម្ភៈ	មីនា	មេសា	ឧសភា	សរុប (TOTAL)	
	RICE EXPORTERS	JAN	FEB	MAR	APR	MAY	MT	%
1	KHMER FOODS GROUP CO.,LTD.	5,161	6,577	9,134			20,872	12.87
2	NIKOLINE INVESTMENT CO., LTD.	4,656	7,825	5,364			17,845	11.00
3	BAITANG (KAMPUCHEA) PLC.	4,046	1,115	7,170			12,331	7.60
4	AMRU RICE (CAMBODIA) CO.,LTD	4,342	3,927	3,194			11,463	7.07
5	CRISTAL RICE (Kampuchea) co., ltd.	1,903	2,798	4,897			9,598	5.92

6	CITY RICE IMPORT EXPORT CO., LTD.	2,069	2,954	2,981		8,004	4.93
7	T.O.T (TRUST OUR TRADE) CO., LTD.	2,411	2,356	3,045		7,812	4.82
8	INTERNATIONAL RICE TRADING (CAMBODIA) CO.,LTD.	2,223	2,483	3,003		7,709	4.75
9	GOLDEN RICE (CAMBODIA) CO.,LTD.	2,736	1,749	2,611		7,096	4.37
10	SIGNATURES OF ASIA CO.,LTD	1,396	2,014	3,111		6,521	4.02
11	GOLDEN DAUN KEO RICE MILL CO., LTD	425	2,920	1,053		4,398	2.71
12	SSCORP(CAMBODIA) CO.,LTD	806	1,518	1,760		4,084	2.52
13	LOR EAK HENG SEK MEAS RICE CO., LTD	987	749	2,099		3,835	2.36
14	HUNG HIEP (CAMBODIA) CO., LTD	1,886	842	912		3,640	2.24
15	APSARA RICE (CAMBODIA) CO., LTD	258	543	2,584		3,385	2.09
16	INDOCHINA RICE MILL LIMITED	951	1,101	1,309		3,361	2.07
17	MEKONG ORYZA TRADING		1,124	2,094		3,218	1.98
18	W.K.R TRADING CO.,LTD	826	1,247	990		3,063	1.89
19	WHITE GOLD IMPORT EXPORT CO,. LTD.	255	1,200	1,132		2,587	1.59
20	THMOR KORL RICE IMPORT EXPORT CO., LTD	920	920	690		2,530	1.56
21	KHY THAY CORPORATION CO.,LTD.	754	754	550		2,058	1.27
22	GUOHONG (CAMBODIA) INDUSTRY Co.,LTD.		500	1,250		1,750	1.08
23	CK RICE TRADING CO., LTD.	615	516	513		1,644	1.01
24	ANGKOR KASEKAM ROONGROEUNG CO.,LTD.	443	446	738		1,627	1.00
25	ANDURIZ (CAMBODGE) SARL	470	675	474		1,619	1.00
26	BATTAMBANG RICE INVESTMENT CO., LTD	400	133	569		1,102	0.68
27	LIM KHEANG HOUT IMPORT EXPORT CO., LTD.	100	248	681		1,029	0.63
28	COMMODITY IN FOCUS CO., LTD.	194	225	550		969	0.60
29	AMRU AND HANWHA INTERNATIONAL	298	294	274		866	0.53
30	PHOU POY DEVELOPMENT IMPORT EXPORT CO., LTD	399	145	167		711	0.44
31	FED RICE BATTAMBANG LTD	100	350	175		625	0.39
32	CAPITAL FOOD INVESTMENT IMPORT EXPORT CO., LTD.		517			517	0.32
33	VONG BUNHENG IMPORT EXPORT CO., LTD	321	120	48		489	0.30
34	T T MILLER TECH (CAMBODIA) CO., LTD			455		455	0.28
35	BAYON CEREAL CO., LTD	97	150	173		420	0.26
36	BOOST RICHE (CAMBODIA) CO., LTD.	297		72		369	0.23
37	GLOBAL ECOLOGICAL RICE (CAMBODIA) CO., LTD	289				289	0.18
38	MEI JING RICE (CAMBODIA) CO., LTD		248			248	0.15
39	DOMNAK TEUK GROUP CO.,LTD	144	72	24		240	0.15
40	OU TONG DEVELOPMENT (CAMBODIA) CO., LTD	92	23	114		229	0.14
41	AROMA RICE IMPORT EXPORT CO.,LTD	71	50	71		192	0.12
42	LIM HENG LEAP TRADING CO.,LTD	50	50	50		150	0.09
43	SAHAKREAS CEDAC LTD	60	60	21		141	0.09
44	KAMPONG THOM RICE MILL LIMITED.		75	50		125	0.08
45	CAM-GRAIN DEVELOPMENT CO., LTD.	100	20			120	0.07
46	Branch of CHONGQING(FT&ECP) GROUP Co., Ltd.	100				100	0.06
47	OVERSEAS FOODS IMPORT EXPORT CO.,LTD	50	48			98	0.06
48	SOMA TRADING COMPANY LIMITED	97				97	0.06
49	AIMS GRAIN ASIA LTD.	92				92	0.06
50	CAVIFOODS co., ltd (Cambodia Vietnam foods)		48	24		72	0.04
51	LK INTERNATIONAL GROUP PLC.		41	24		65	0.04
52	BAYON JASMINE RICE CO.,LTD		48			48	0.03
53	MILIN RICE (CAMBODIA) IMPORT EXPORT CO.,LTD		47			47	0.03
54	JING MI RICE MILL CO., LTD	46				46	0.03
55	YAMCHANN RICE CO., LTD.	46				46	0.03
56	MUFAVOR INTERNATIONAL (CAMBODIA) INC.		25	20		45	0.03
57	XIANGSHAN RICE (Cambodia) co.,ltd.			30		30	0.02
58	TECH SOON AGRO INDUSTRY CO.,LTD			25		25	0.02
59	SOK KEO IMPORT EXPORT CO., LTD	24				24	0.01
60	CAMBODIAN LI SHINE international trade co.,ltd		22			22	0.01
61	KHUN NGUON RICE EXPORT co., ltd.	20				20	0.01
62	HUA FENG YUAN rice vermicelli (Cam) industrial co.,ltd	7				7	0.00
	GRAND TOTAL	44,026	51,912	**66,275**		162,220	100.00

ភ្នាក់ងារ និង ឯកភាព
ប្រធានលេខាធិការដ្ឋាន
ច្រកចេញចូលតែមួយសម្រាប់បំពេញបែបបទនាំចេញអង្ករ

បណ្ឌិត ហ៊ាន វណ្ណហាន

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ មេសា ឆ្នាំ២០១៦
អ្នករៀបចំសរុបទិន្នន័យ

ឌិន ឌារ៉ូ